# ព្រះរាជាណាចក្រកម្ពុជា
## ជាតិ សាសនា ព្រះមហាក្សត្រ

ក្រសួងឧស្សាហកម្ម និងសិប្បកម្ម
Ministry of Industry & Handicraft
លេខ: ៥៧៣ MIH / 2014

## ប្រកាស
## ស្តីពី
## ការរៀបចំ និងការប្រព្រឹត្តទៅរបស់ក្រុមប្រឹក្សាជាតិវាយតម្លៃទទួលស្គាល់

## ទេសរដ្ឋមន្ត្រី រដ្ឋមន្ត្រីក្រសួងឧស្សាហកម្ម និងសិប្បកម្ម

- បានឃើញរដ្ឋធម្មនុញ្ញនៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/០៩១៣/៩០៣ ចុះថ្ងៃទី២៤ ខែកញ្ញា ឆ្នាំ២០១៣ ស្តីពីការតែងតាំងរាជរដ្ឋាភិបាលនៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/១២១៣/១៣៩៣ ចុះថ្ងៃទី២១ ខែធ្នូ ឆ្នាំ២០១៣ ស្តីពីការកែសម្រួល និងបំពេញបន្ថែមសមាសភាពរាជរដ្ឋាភិបាលនៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រមលេខ ០២/នស/៩៤ ចុះថ្ងៃទី២០ ខែកក្កដា ឆ្នាំ១៩៩៤ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពី ការរៀបចំ និងការប្រព្រឹត្តទៅនៃគណៈរដ្ឋមន្ត្រី
- បានឃើញព្រះរាជក្រមលេខ នស/រកម/១២១៣/០១៨ ចុះថ្ងៃទី០៦ ខែធ្នូ ឆ្នាំ២០១៣ ដែលប្រកាសឱ្យប្រើច្បាប់ ស្តីពីការបង្កើតក្រសួងឧស្សាហកម្ម និងសិប្បកម្ម
- បានឃើញព្រះរាជក្រមលេខ នស/រកម/០៦០៧/០១៣ ចុះថ្ងៃទី២៤ ខែមិថុនា ឆ្នាំ២០០៧ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីស្តង់ដារកម្ពុជា
- បានឃើញអនុក្រឹត្យលេខ ៥៧៥ អនក្រ.បក ចុះថ្ងៃទី២៤ ខែធ្នូ ឆ្នាំ២០១៣ ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅរបស់ក្រសួងឧស្សាហកម្ម និងសិប្បកម្ម
- បានឃើញប្រកាសលេខ ៤៣៥ MIH / 2014 ចុះថ្ងៃទី ២៧ ខែឧសភា ឆ្នាំ២០១៤ ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅរបស់នាយកដ្ឋានវាយតម្លៃទទួលស្គាល់
- យោងតាមការងារចាំបាច់របស់ក្រសួង

## សម្រេច

**ប្រការ១.**

ត្រូវបានបង្កើតក្រុមប្រឹក្សាជាតិវាយតម្លៃទទួលស្គាល់ (ក.ជ.វ.ទ.ស) Cambodian Accreditation National Council (CANC) ដែលមានសមាសភាពដូចខាងក្រោម៖

| | | |
|---|---|---|
| ១- ឯកឧត្តម **ចម ប្រសិទ្ធ** | ទេសរដ្ឋមន្ត្រី តំណាងក្រសួងឧស្សាហកម្ម និងសិប្បកម្ម | ប្រធាន |
| ២- ឯកឧត្តម **សឹម ណារ៉ា** | អគ្គនាយក នៃអគ្គនាយកដ្ឋានឧស្សាហកម្ម | អនុប្រធាន |
| ៣- លោក **ហ៊ាន វណ្ណហន** | តំណាងក្រសួងកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ | អនុប្រធាន |
| ៤-ឯកឧត្តមសាស្ត្រាចារ្យជំនួយ **ចាន់ ស៊ីវ៉ាន់ថា** | តំណាងក្រសួងសុខាភិបាល | អនុប្រធាន |
| ៥- លោក **គឹម មាសសុខសីហា** | តំណាងក្រសួងពាណិជ្ជកម្ម | អនុប្រធាន |
| ៦- លោក **ជៀន សេងគង់** | ប្រធាននាយកដ្ឋានវាយតម្លៃទទួលស្គាល់ | សមាជិកអចិន្ត្រៃយ៍ |
| ៧- លោក **ឡុង រិទ្ធីរក្ស** | តំណាងក្រសួងបរិស្ថាន | សមាជិក |
| ៨- ឯកឧត្តម **ពេជ្រ សម្បត្តិ** | តំណាងក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ | សមាជិក |



ក្រសួងឧស្សាហកម្ម និងសិប្បកម្ម
៤៥ មហាវិថីព្រះនរោត្តម
សង្កាត់ផ្សារថ្មី ៣ ខណ្ឌដូនពេញ
ភ្នំពេញ ១២២០៥ (ព្រះរាជាណាចក្រកម្ពុជា)

ខុទ្ទកាល័យឯកឧត្តម ទេសរដ្ឋមន្ត្រី
ទូរស័ព្ទលេខ: (៨៥៥) ២៣ ២១១ ៧៧៥
ទូរសារលេខ: (៨៥៥) ២៣ ៤២៨ ២៦៣
អ៊ីមែល: mih.smcabinet@gmail.com

| | | | |
|---|---|---|---|
| ៩- ឯកឧត្តម | **អោក មុនី** | តំណាងក្រសួងមហាផ្ទៃ | សមាជិក |
| ១០- លោក | **ឈុន ពុទ្ធារិទ្ធ** | តំណាងក្រសួងធនធានទឹក | សមាជិក |
| ១១- ឯកឧត្តម | **វ៉ាស៊ីម សុរិយា** | តំណាងក្រសួងសាធារណៈការ និងដឹកជញ្ជូន | សមាជិក |
| ១២- លោក | **នួន ច័ន្ទរិទ្ធ** | តំណាងអគ្គនាយកដ្ឋានគយ និងរដ្ឋាករកម្ពុជា | សមាជិក |
| ១៣- លោក | **ប៉ូវ ប៉ុនណារ៉ា** | តំណាងអគ្គនាយកដ្ឋានគយ និងរដ្ឋាករកម្ពុជា | សមាជិក |
| ១៤- លោកបណ្ឌិត | **សង់ ស៊ីណាវិទ្យ** | តំណាងអគ្គនាយកដ្ឋានគយ និងរដ្ឋាករកម្ពុជា | សមាជិក |
| ១៥- ឯកឧត្តម | **ជា សុខឃាង** | តំណាងសមាគមគ្រឹះស្ថានឧត្តមសិក្សាកម្ពុជា | សមាជិក |
| ១៦- លោក | **អ៊ុក សុភាព** | តំណាងអគ្គិសនីកម្ពុជា | សមាជិក |
| ១៧- លោក | **ចាន់ ពិសិដ្ឋ** | តំណាងរដ្ឋាករទឹកស្វយ័តក្រុងភ្នំពេញ | សមាជិក |
| ១៨- លោក | **ងួន ម៉េងតិច** | តំណាងសភាពាណិជ្ជកម្មកម្ពុជា | សមាជិក |
| ១៩- លោក | **លិប ជាង** | តំណាងសម្ព័ន្ធសមាគមសហគ្រាសធុនតូច និងមធ្យមកម្ពុជា | សមាជិក |
| ២០- លោក | **Amnat Pisutsin** | តំណាងអង្គភាពវាយតម្លៃភាពអនុលោម | សមាជិក |

**ប្រការ២.**

ក្រុមប្រឹក្សាជាតិវាយតម្លៃទទួលស្គាល់ (ក.ជ.វ.ទ.ស) មានភារកិច្ចដូចតទៅ ៖

- ពិភាក្សា និងផ្តល់យោបល់អំពីគោលនយោបាយ និងផែនការយុទ្ធសាស្ត្រក្នុងការអនុវត្តការងារវាយតម្លៃទទួលស្គាល់របស់នាយកដ្ឋានវាយតម្លៃទទួលស្គាល់ ដើម្បីដាក់ជូនរដ្ឋមន្ត្រីក្រសួងឧស្សាហកម្ម និងសិប្បកម្ម ពិនិត្យ និងសម្រេច
- ពិភាក្សា និងផ្តល់យោបល់អំពីកម្មវិធីការងារ គម្រោងថវិកាប្រចាំឆ្នាំ និងរបាយការណ៍ប្រចាំឆ្នាំ របស់នាយកដ្ឋានវាយតម្លៃទទួលស្គាល់ ដើម្បីស្នើសុំការយល់ព្រមពីក្រសួង
- ពិនិត្យមើលរចនាសម្ព័ន្ធ បែបបទ និងនិតិវិធី ដែលរៀបចំឡើងដោយនាយកដ្ឋានវាយតម្លៃទទួលស្គាល់
- ពិនិត្យតាមដាននូវរាល់កិច្ចដំណើរការរបស់នាយកដ្ឋានវាយតម្លៃទទួលស្គាល់ សំដៅធានាអះអាងចំពោះមុខក្រសួងស្ថាប័នពាក់ព័ន្ធ និងអង្គការអន្តរជាតិនានានូវរាល់កិច្ចដំណើរការ និងការសម្រេចចិត្តនានារបស់នាយកដ្ឋានប្រព្រឹត្តទៅដោយឯករាជ្យ និងមិនលម្អៀងទៅតាមលិខិតបទដ្ឋានគតិយុត្តិដែលមានជាធរមាន និងអនុលោមតាមស្តង់ដារជាតិ និងអន្តរជាតិ
- បង្កើតគណៈកម្មការដោះស្រាយរាល់ការតវ៉ាដោយអង្គភាពវាយតម្លៃភាពអនុលោម ឬអ្នកប្រើប្រាស់លើការសម្រេចចិត្តរបស់ប្រធាននាយកដ្ឋានវាយតម្លៃទទួលស្គាល់
- ធានាគុណភាព ប្រសិទ្ធភាព តម្លាភាព នៃលទ្ធផលបំពេញការងារចុះបញ្ជីវាយតម្លៃទទួលស្គាល់ និងការងារវាយតម្លៃទទួលស្គាល់
- បង្កើតនូវភាពជឿជាក់ និងទំនុកចិត្តដល់ភាគីពាក់ព័ន្ធលើសមត្ថភាពអង្គភាពវាយតម្លៃភាពអនុលោមគ្រប់កម្រិតខ្នាត ដើម្បីឱ្យអ្នកប្រើប្រាស់ទទួលបាននូវផលិតផល ឬទំនិញមានគុណភាព សុវត្ថិភាព និងផាសុខភាព។

**ប្រការ៣.**

សមាជិកក្រុមប្រឹក្សាជាតិវាយតម្លៃទទួលស្គាល់ ត្រូវចូលរួមប្រជុំឱ្យបានទៀងទាត់តាមការអញ្ជើញរបស់ប្រធានក្រុមប្រឹក្សាជាតិវាយតម្លៃទទួលស្គាល់។ សម័យប្រជុំក្រុមប្រឹក្សាជាតិអាចប្រព្រឹត្តទៅបានលុះត្រាតែមានកូរ៉ុមលើសពីពាក់កណ្តាល នៃសមាជិកសរុប។ រាល់សេចក្តីសម្រេចណាមួយរបស់ក្រុមប្រឹក្សាជាតិត្រូវប្រព្រឹត្តទៅដោយមតិភាគច្រើនពីភាគបីនៃសមាជិកវត្តមានក្នុងកិច្ចប្រជុំរបស់ក្រុមប្រឹក្សាជាតិ។ នៅពេលប្រធានអវត្តមាន ក្រុមប្រឹក្សាជាតិវាយតម្លៃ

ទទួលស្គាល់អាចធ្វើការប្រជុំទៅបានក្រោមការដឹកនាំរបស់អនុប្រធានក្រុមប្រឹក្សា ឬសមាជិកតំណាងណាម្នាក់ដែលបានទទួលការប្រគល់សិទ្ធិពីប្រធាន។

**ប្រការ៤.**_

ក្រុមប្រឹក្សាជាតិវាយតម្លៃទទួលស្គាល់ អាចបង្កើតគណៈកម្មការបច្ចេកទេសវាយតម្លៃទទួលស្គាល់ អនុគណៈកម្មការបច្ចេកទេសវាយតម្លៃទទួលស្គាល់ ឬក្រុមការងារវាយតម្លៃទទួលស្គាល់ទៅតាមវិស័យនីមួយៗបាន ដើម្បីជួយបំពេញមុខងារ និងភារកិច្ច ឬសម្រាប់គោលបំណងផ្សេងទៀតដែលកើតឡើង ឬដែលទាក់ទិនដល់មុខងារ និងភារកិច្ចរបស់ខ្លួន។

**ប្រការ៥.**_

ក្រុមប្រឹក្សាជាតិវាយតម្លៃទទួលស្គាល់ មាននាយកដ្ឋានវាយតម្លៃទទួលស្គាល់ជាលេខាធិការដ្ឋានធ្វើការសម្របសម្រួលរាល់ការងារទាំងអស់នៃក្រុមប្រឹក្សាជាតិវាយតម្លៃទទួលស្គាល់។

**ប្រការ៦.**_

ក្នុងករណីសមាជិកក្រុមប្រឹក្សាជាតិវាយតម្លៃទទួលស្គាល់ណាម្នាក់អវត្តមាននៅក្នុងកិច្ចប្រជុំនោះ មានន័យថាសមាជិកនោះបានឯកភាពទៅលើអ្វីដែលកិច្ចប្រជុំបានអនុម័ត។

**ប្រការ៧.**_

បទប្បញ្ញត្តិទាំងឡាយណា ដែលមានខ្លឹមសារផ្ទុយនឹងប្រកាសនេះ ត្រូវចាត់ទុកជានិរាករណ៍។

**ប្រការ៨.**_

នាយកខុទ្ទកាល័យ អគ្គនាយក អគ្គាធិការ ប្រធានវិទ្យាស្ថាន ប្រធានមជ្ឈមណ្ឌល ប្រធាននាយកដ្ឋានវាយតម្លៃទទួលស្គាល់ គ្រប់អង្គភាពពាក់ព័ន្ធ និងឯកឧត្តម អស់លោក លោកស្រី ដែលមានឈ្មោះក្នុងប្រការ១ មានភារកិច្ចអនុវត្តប្រកាសនេះ ចាប់ពីថ្ងៃចុះហត្ថលេខាតទៅ។

រាជធានីភ្នំពេញ, ថ្ងៃទី ០៦ ខែកញ្ញា ឆ្នាំ២០១៤

**ទេសរដ្ឋមន្ត្រី**

**រដ្ឋមន្ត្រីក្រសួងឧស្សាហកម្ម និងសិប្បកម្ម**

**ចម ប្រសិទ្ធ**

**កន្លែងទទួល ៖**

- ខុទ្ទកាល័យសម្តេចអគ្គមហាសេនាបតីតេជោ **ហ៊ុន សែន**
- ទីស្តីការគណៈរដ្ឋមន្ត្រី
- ក្រសួង ស្ថាប័នពាក់ព័ន្ធ

  « *ដើម្បីជូនជ្រាប* »
- ដូចប្រការ៨

  « *ដើម្បីអនុវត្ត* »
- ឯកសារ-កាលប្បវត្តិ